# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Mar-2012, 15:58
CMS/CFO: Kauv Keoratanak

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់ នួន ជា សុំស្តាប់ចម្លើយសាក្សីដែលបានស្នើដោយមេធាវីការពារក្តី និងចាត់វិធានការខាងនីតិវិធីផ្សេងទៀត ដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវលើបរិបទប្រវត្តិសាស្ត្រ"**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS

| | |
|---|---|
| Elisabeth SIMONNEAU FORT | លោក គង់ សំអុន |
| | Anta GUISSE |
| | លោក Arthur VERCKEN |
| | លោក Jacques VERGÈS |

## I. សេចក្ដីផ្ដើម

១- នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ មេធាវីការពារក្ដី នួន ជា ("មេធាវីការពារក្ដី" ) បានដាក់*សំណើក្លាយ សុំស្ដាប់ចម្លើយសាក្សីស្នើដោយមេធាវីការពារក្ដី និងចាត់វិធានការខាងនីតិវិធីផ្សេងទៀត ដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវលើបរិបទប្រវត្តិសាស្ត្រ* ("សំណើរ")[1]។ នៅក្នុងសំណើនេះ មេធាវីការពារក្ដីបានស្នើដល់អង្គជំនុំជម្រះសាលាដំបូង "(i) កុំទាន់បិទវគ្គសវនាការស្ដីពីសាវតារប្រវត្តិសាស្ត្រ និង (ii) កោះហៅសាក្សី និងអ្នកជំនាញរបស់មេធាវីការពារក្ដីដែលសក្ខីកម្មរបស់ពួកគាត់មានការពាក់ព័ន្ធ ដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវលើសាវតារប្រវត្តិសាស្ត្រ"[2]។ សំណើនេះបង្ហាញពីរបៀបដែលព័ត៌មានប្រវត្តិសាស្ត្រជាក់លាក់ខ្លះ និងសាក្សីបន្ថែម អាចនឹងមានការពាក់ព័ន្ធទៅនឹងសវនាការនេះ។

២- នៅក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើនេះមានការសន្មតទៅលើការយល់ច្រឡំមួយដែលថា សាក្សីក្នុងពេលអនាគត មិនអាចលើកបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រ។ ជាគោលការណ៍ សហព្រះរាជអាជ្ញាមិនជំទាស់នឹងការកោះហៅសាក្សី និងអ្នកជំនាញបន្ថែមក្នុងចំនួនមួយមានកំណត់នោះទេ ស្ដីពីអំពីបញ្ហានេះ បើសិនជា: មាននីតិវិធីសមស្របដើម្បីកំណត់ថាតើសាក្សីទាំងនោះជានរណា; ការពិចារណាទៅលើសេចក្ដីសន្និដ្ឋានមុនៗរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងសាក្សី និងសេចក្ដីសន្និដ្ឋានចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូង អំពីអត្ថប្រយោជន៍ និងភាពចាំបាច់នៃការកោះហៅសាក្សីបន្ថែម។ ប៉ុន្តែក្នុងករណីនេះ សហព្រះរាជអាជ្ញាជឿថា ចំនួនសាក្សីបន្ថែមដែលបានស្នើឡើងដោយមេធាវីការពារក្ដី គឺមានចំនួនកើនឡើងច្រើនហួសហេតុចំពោះយុត្តិកម្មដែលអាចមានណាមួយ និងជាការប៉ុនប៉ងដើម្បីបង្អាក់ និងពន្យារពេលដល់សវនាការនេះ។ ការប៉ុនប៉ងមួយធ្វើឡើងដោយ នួន ជា និងមេធាវីការពារក្ដីរបស់គាត់ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ដើម្បីគំរាមដល់តុលាការ តាមរយៈការបដិសេធមិនឆ្លើយនឹងសំណួរផ្សេងៗ វៀរលែងតែអង្គជំនុំជម្រះអនុញ្ញាតតាមសំណើនេះ បង្ហាញឲ្យឃើញបន្ថែមទៀតថា មេធាវីការពារក្ដីមិនមែនកំពុងតែធ្វើសកម្មភាពដោយសុចរិតពាក់ព័ន្ធនឹងករណីនេះឡើយ។

៣- ជាងនេះទៀត បញ្ហាទាំងឡាយដែលបានលើកឡើងតាមសំណើនេះគឺជាកម្មវត្ថុនៃការដាក់ឯកសារពីមុនជាច្រើនធ្វើឡើងដោយមេធាវីការពារក្ដី នៅគ្រប់ដំណាក់កាលនិមួយៗនៃកិច្ចដំណើរការនីតិវិធីទាំងនេះ

---

[1] **E182** សំណើរបស់ នួន ជា សុំស្ដាប់ចម្លើយសាក្សីដែលបានដោយស្នើមេធាវីការពារក្ដី និងចាត់វិធានការខាងនីតិវិធីផ្សេងទៀត ដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវអំពីបរិបទប្រវត្តិសាស្ត្រ, ១៦ មីនា ២០១១ ("សំណើ")។

[2] **E182** សំណើ កំណត់សម្គាល់*ខាងដើម* លេខ១ ត្រង់កថាខណ្ឌទី១។

ហើយត្រូវបានពិចារណា និងសម្រេចយ៉ាងត្រឹមត្រូវរួចហើយ ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស" ឬ "សចស"), អង្គបុរេជំនុំជម្រះ ("អបជ") និងអង្គជំនុំជម្រះសាលាដំបូង។ មេធាវីការពារក្ដីមានឱកាសបង្ហាញសក្ខីកម្មពីជនជាប់ចោទ និងភ័ស្ដុតាងឯកសារចំពោះបញ្ហាទាំងនេះ នៅក្នុងវគ្គដំបូងនៃសវនាការស្ដីពីសារតារប្រវត្តិសាស្ត្រ និងមានឱកាសចោទសំណួរផ្សេងៗចំពោះសាក្សីទាំងអស់ជាបន្តបន្ទាប់នៅលើបញ្ហាទាំងនេះ។ សាក្សីទាំងនោះ រួមបញ្ចូលទាំងអតីតកម្មាភិបាលរបស់ បកក ជាង៥០នាក់ ជនស៊ីវិលមួយចំនួនដែលធ្លាប់រស់នៅទីក្រុងភ្នំពេញនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងអ្នកជំនាញមួយចំនួនទៀតដែលដឹងនឹងស្ថានភាពនៅកម្ពុជា ក្នុងរយៈកាលនៅមុនឆ្នាំ១៩៧៥។ ដោយសារមូលហេតុទាំងនេះ សិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់មេធាវីការពារក្ដីមិនទាន់បានស្រុះស្រួលគ្នានៅឡើយទេ ហើយការស្ដាប់សក្ខីកម្មចំពោះសាក្សីបន្ថែមរបស់ខ្លួន គឺជាការមិនចាំបាច់។

## II. ប្រវត្តិនីតិវិធី

### ក. កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ កសចស និង អបជ

៤- នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ មេធាវីការពារក្ដីបានដាក់សំណើមួយស្នើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងសកម្មភាពផ្សេងៗរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក (ជាមួយនឹងរដ្ឋផ្សេងទៀត) នៅកម្ពុជា ក្នុងសម័យកាលមុនឆ្នាំ១៩៧៥[3]។ សចស បានផ្ដល់ការអនុញ្ញាតតាមសំណើជាច្រើនរបស់មេធាវីការពារក្ដី ដោយគូសបញ្ជាក់ថា ខ្លួនបានបញ្ជូនដីកាចាត់ឲ្យស៊ើបសួរជំនួសទៅសហរដ្ឋអាមេរិក និងប្រទេសផ្សេងទៀតដែលពួកគាត់គិតថា ទំនងជាមានព័ត៌មានពាក់ព័ន្ធ[4]។ ជាលទ្ធផលនៃកិច្ចស៊ើបសួររបស់ កសចស ឯកសារមួយចំនួនធំត្រូវបានទទួលពីសំណុំឯកសាររបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក និងបារាំងដែលពាក់ព័ន្ធនឹងសម័យកាលកម្ពុជាប្រជាធិបតេយ្យ និងមុនសម័យកាលឆ្នាំ១៩៧៥[5]។

---

[3] **D105** សំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំ, ២៦ កញ្ញា ២០០៨។

[4] **D315** ដីកាសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួររបស់ នួន ជា ទាក់ទិននឹងរដ្ឋបរទេស (D101, D102, D105, D126 & D128), ១៣ មករា ២០១០ ត្រង់កថាខណ្ឌទី 19-20, 25-27, 32-35; **D291** ដីកាចាត់ឲ្យស៊ើបសួរជំនួសជាអន្តរជាតិ, ៨ សីហា ២០០៨; **D291/3** លិខិតពី កសចស ជូនស្ថានទូតសហរដ្ឋអាមេរិក, ២៨ កក្កដា ២០០៩ (រួមមានសំណើសុំឯកសារទាក់ទិននឹង "ស្ថានភាពសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា" ទាំង "នៅមុន និងក្រោយខែមេសា ឆ្នាំ១៩៧៥")។

[5] សហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណឯកសារជាង២៥០ នៅក្នុងសំណុំរឿង ដែលចេញពីក្រសួងការបរទេសអាមេរិក, ស្ថានទូតអាមេរិកនៅភ្នំពេញ និងបាំងកក, ក្រុមប្រឹក្សាសន្តិសុខជាតិ និងសេតវិមាន។ ឯកសារខ្លះត្រូវបានផលិតឡើងដោយផ្ទាល់ដោយរដ្ឋាភិបាលអាមេរិក នៅក្នុងករណីនេះ (គឺឯកសារដែលមានលេខ "D291" នៅត្រង់លេខចាប់ផ្ដើមនៃសំណុំរឿង), ខណៈដែលឯកសារផ្សេងទៀតត្រូវ

៥- មេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ទាក់ទងនឹងសំណើសុំបំពេញកិច្ចស៊ើបសួរនានាដែលត្រូវបានបដិសេធ[6]។ នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០ អបជ បានច្រានចោលបណ្តឹងឧទ្ធរណ៍នោះ ដោយបានរកឃើញថា សចស មានសិទ្ធិបដិសេធសំណើទាំងឡាយណាដែល "មានភាពមិនច្បាស់លាស់" និងតម្រូវឲ្យធ្វើការស៊ើបសួរទៅលើ "ប្រភេទឯកសារភ័ស្តុតាងលម្អិត" និង សចស "មានសិទ្ធិពិចារណាថាតើសំណើអាចបង្កឲ្យមានការពន្យារពេលមិនសមរម្យណាមួយ ឬទេ បើសិនជាត្រូវអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន តាមស្មារតីនៃកិច្ចស៊ើបសួរទាំងមូលនោះ"[7]។ អបជ ក៏បានធ្វើការសន្និដ្ឋានជាចុងក្រោយមួយដែរថា សចស មិនតម្រូវឲ្យស៊ើបអង្កេតពី "ចំនួននៃការស្លាប់ដែលបណ្តាលមកពីបេសកកម្មទម្លាក់គ្រាប់បែកនៃកងកម្លាំងទ័ពអាកាសអាមេរិកនៅកម្ពុជាទេ" ដោយហេតុថា ការពិតការទម្លាក់គ្រាប់បែកដូច្នេះពិតជាកើតមានមែន (មិនមានចំនួនពិតប្រាកដនៃការស្លាប់បណ្តាលមកពីការទម្លាក់គ្រាប់បែកនោះទេ) ដែលពាក់ព័ន្ធទៅនឹងទ្រឹស្តីនៃការដោះបន្ទុកដែលបានបង្ហាញដោយមេធាវីការពារក្តី[8]។

៦- នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៩ មេធាវីការពារក្តីបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរមួយ ដោយស្នើសុំព័ត៌មាន និងសម្ភារៈទាក់ទងនឹងការផ្គត់ផ្គង់អាហារហូបចុក និងលក្ខខណ្ឌរស់នៅ នៅក្នុងប្រទេសកម្ពុជា នៅមុន និងក្នុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[9]។ ភាគច្រើនបំផុតនៃសំណើសុំនេះ ត្រូវបានទទួលយកដោយ កសចស ហើយមានតែពីរផ្នែកប៉ុណ្ណោះដែលត្រូវបានបដិសេធ[10]។ និយាយឲ្យចំ គឺ

---

បានដាក់ឲ្យលែងជាការសម្ងាត់តទៅទៀតដោយអាជ្ញាធរអាមេរិក និងបានលាតត្រដាងជាសាធារណៈ (ឧ. ឯកសារដែលបានដាក់នៅក្នុងឈុតនៃសំណុំឯកសារក្នុងសំណុំរឿងដែលមានលេខ D313, D366 និង D248)។ ក្នុងចំនួនសរុប ៦០៥ ឯកសារ គឺ កសចស បានទទួលពីបណ្ណសារនៃក្រសួងការបរទេសបារាំង។ *សូមអាន* ឯកសារលេខ **D199/3** លិខិតអមរបស់ កសចស, ៧ កញ្ញា ២០០៩; **D199/26** ដីកាសម្រេចដោយសហចៅក្រមស៊ើបអង្កេត, ៨ មករា ២០១០ (ថ្លែងថា ឯកសារត្រូវបានដាក់នៅក្នុងសំណុំរឿង ពាក់ព័ន្ធនឹងសំណើសុំបំពេញកិច្ចស៊ើបសួរ "ទាក់ទិននឹងសម្ព័ន្ធភាពរវាងកម្ពុជា និងរដ្ឋផ្សេងទៀតដែលបានដាក់ដោយក្រុមមេធាវីការពារក្តី នួន ជា")។

[6] **D315/1/1** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ចំពោះសំណើសុំរបស់ នួន ជា សុំឲ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស, ១៥ កុម្ភៈ ២០១០។

[7] **D315/1/5** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ចំពោះសំណើសុំរបស់ នួន ជា សុំឲ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស និងលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចចំពោះសំណើសុំឲ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស, ទាក់ទងនឹងការបដិសេធសំណើសុំស្តាប់ចម្លើយធ្វើឡើងដោយ ខៀវ សំផន, ៧ មិថុនា ២០១០, ត្រង់កថាខណ្ឌទី១៩-២៤។

[8] **D315/1/5** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ចំពោះសំណើសុំរបស់ នួន ជា សុំឲ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស និងលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចចំពោះសំណើសុំឲ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស, ទាក់ទងនឹងការបដិសេធសំណើសុំស្តាប់ចម្លើយធ្វើឡើងដោយ ខៀវ សំផន, ៧ មិថុនា ២០១០, ត្រង់កថាខណ្ឌទី៤៥-៤៧។

[9] **D173** សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២, ៣ មិថុនា ២០០៩។

[10] **D300** ដីកាសម្រេចលើសំណើសុំលេខ D153, D172, D173, D174, D178 & D284, ១២ មករា ២០១០ ត្រង់កថាខណ្ឌ៣១-៣៩។

កសចស បានច្រានចោលសំណើសុំព័ត៌មានពីមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដោយរកឃើញថា សកម្មភាពដូច្នេះអាចជា "ការជាន់គ្នាមិនចាំបាច់" និងមិនផ្តល់ "តម្លៃបន្ថែមដល់កិច្ចស៊ើបសួរទេ"[11] និងសំណើសុំព័ត៌មានពីគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ("ICRC") ដោយផ្អែកលើបុព្វសិទ្ធិជាទម្លាប់ដែលទទួលស្គាល់ចំពោះស្ថាប័ននេះ[12]។

៧- ដីកាសម្រេចរបស់ សចស ជាថ្មីម្តងទៀត ត្រូវបានប្តឹងឧទ្ធរណ៍ដោយមេធាវីការពារក្តី[13]។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ អបជ បានទទួលយកចំពោះបណ្តឹងឧទ្ធរណ៍មួយផ្នែក និងបានបង្គាប់ឱ្យ កសចស ពិចារណាឡើងវិញលើសំណើសុំទាក់ទងនឹង ICRC និងឱ្យផ្តល់ឧទាហរណ៍ផ្សេងចំពោះកិច្ចស៊ើបសួរដែលបានធ្វើឱ្យសំណើសុំពាក់ព័ន្ធនឹង IMF ជា "ការជាន់គ្នាមិនចាំបាច់"[14]។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ កសចស បានចេញដីកាសម្រេចបន្ថែមមួយជាការឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់ អបជ។ ទាក់ទងនឹង ICRC កសចស បានធ្វើការកត់សម្គាល់ថា ខ្លួនបានទាក់ទងទីភ្នាក់ងារដទៃទៀត និងបានទទួលភ័ស្តុតាងដែលមានព័ត៌មានដូចគ្នានឹង ICRC ផ្តល់ជូនដែរ ដែលព័ត៌មាននេះត្រូវបានដាក់ក្នុងសំណុំរឿងរួចហើយ។ ទាក់ទងនឹង IMF វិញ កសចស ក៏បានបញ្ជាក់អះអាងដែរថា កិច្ចស៊ើបសួរបន្ថែមមិនត្រូវបានអនុញ្ញាតទេដោយហេតុថា ព័ត៌មានដែលអាចរកបាននៅ IMF ទាក់ទិននឹងសម័យកាលនោះបន្ទាប់ពីព្រឹត្តិការណ៍ កំពុងស្ថិតក្រោមកិច្ចស៊ើបសួរ[15]។ មេធាវីការពារក្តីក៏បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទីពីរនេះទៀតដែលចេញដោយ កសចស[16] តែបណ្តឹងឧទ្ធរណ៍នេះត្រូវបានបដិសេធដោយ អបជ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០[17]។

---

[11] **D300** ដីកាសម្រេចលើសំណើសុំលេខ D153, D172, D173, D174, D178 & D284, ១២ មករា ២០១០ ត្រង់កថាខណ្ឌ៣៤។

[12] **D300** ដីកាសម្រេចលើសំណើសុំលេខ D153, D172, D173, D174, D178 & D284, ១២ មករា ២០១០ ត្រង់កថាខណ្ឌ៣៥។

[13] **D300/1/1** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំលេខ D153, D172, D173, D174, D178 និង D284, (សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី២០ របស់ នួន ជា, ១១ កុម្ភៈ ២០១០)។

[14] **D300/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំលេខ D153, D172, D173, D174, D178 និង D284, (សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ នួន ជា, ១៥ មិថុនា ២០១០)។

[15] **D300/3** ដីកាសម្រេចអំពីការណែនាំឱ្យពិចារណាឡើងវិញអំពីដីកាសម្រេចលើសំណើសុំលេខ D153, D172, D173, D174, D178 និង D284 (សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ នួន ជា), ២១ មិថុនា ២០១០, ត្រង់កថាខណ្ឌទី៨។

[16] **D300/1/3** សេចក្តីជូនដំណឹងអំពីបំណងបន្តបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ នួន ជា, ២៣ មិថុនា ២០១០; **D300/1/4** សារណាបណ្តឹងឧទ្ធរណ៍បន្ថែមប្រឆាំងនឹងដីការបស់ កសចស សម្រេចអំពីសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ នួន ជា, ២៨ មិថុនា ២០១០។

[17] **D300/1/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស អំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំលេខ D153, D172, D173, D174, D178 និង D284, ១៤ កក្កដា ២០១០។

## ខ. កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

៨- នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឲ្យភាគីផ្តល់ព័ត៌មានស្តីពីសាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់ដែលបានស្នើឡើង[18]។ ភាគីតម្រូវឲ្យផ្តល់ព័ត៌មានសម្រាប់សាក្សីម្នាក់ៗ *នូវ* "រយៈពេលប៉ាន់ស្មានដែលត្រូវការដើម្បីឲ្យសាក្សីបំភ្លឺ", "សេចក្តីសង្ខេបនៃអង្គហេតុដែលសាក្សីម្នាក់ៗដែលបានស្នើឡើងនោះ នឹងមកបំភ្លឺ" ដែលមាន "លក្ខណៈលម្អិតគ្រប់គ្រាន់ដើម្បីឲ្យអង្គជំនុំជម្រះ និងភាគីដទៃទៀតយល់បានពេញលេញអំពីចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្មដែលបានស្នើឡើងនោះ" និង "ចំណុចផ្សេងៗនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញម្នាក់ៗដែលបានស្នើឡើងនោះ នឹងត្រូវមកបំភ្លឺ រួមទាំង បើសិនជាអាចកថាខណ្ឌជាក់លាក់នៃដីកាដំណោះស្រាយ និងបទចោទជាក់លាក់"[19]។

៩- មេធាវីការពារក្តីតវ៉ាថា សំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំព័ត៌មាននេះគឺ "គ្មានមូលដ្ឋានខាងផ្លូវច្បាប់"ទេ[20] ប៉ុន្តែទោះជាយ៉ានេះក្តី មេធាវីការពារក្តីអនុវត្តតាមមួយផ្នែកនៃសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងនេះ។ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់បញ្ជីឈ្មោះសាក្សីចំនួន៥២៧នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦នាក់ និងអ្នកជំនាញចំនួន១៣នាក់[21]។ នៅក្នុងចំណោមសាក្សីទាំង៥២៧នាក់ដែលមេធាវីការពារក្តីបានស្នើឡើងនេះ យ៉ាងហោចណាស់មានសាក្សីចំនួន១៣៤នាក់ ត្រូវបានគេកំណត់អត្តសញ្ញាណថា មានការពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រ។ សេចក្តីរៀបរាប់ទាំងស្រុងដែលបានផ្តល់ចំពោះបុគ្គលទាំងអស់នោះគឺ "ស្ថានភាពមុនឆ្នាំ១៩៧៥", "ស្ថានភាពក្រោយឆ្នាំ១៩៧៥", "ការពាក់ព័ន្ធរបស់សហរដ្ឋអាមេរិក", និង/ឬ "ការពាក់ព័ន្ធរបស់ ស៊ីអាយអេ"។ បញ្ជីរបស់មេធាវីការពារក្តី បានដាក់បញ្ចូលអ្នកការទូតចំនួន៧៣រូប, មន្ត្រីរដ្ឋាភិបាលបរទេសចំនួន៥៧រូប, បុគ្គលិកស្ថានទូតចំនួន១៩រូប, បុគ្គលិកអង្គការអន្តរជាតិចំនួន៥៩រូប, សមាជិកគណបក្សនយោបាយបរទេសចំនួន១៥រូប, គណៈប្រតិភូបរទេសចំនួន១១រូប, អ្នកស្រាវជ្រាវជាន់ខ្ពស់ ឬប្រវត្តិវិទូចំនួន៣០រូប និងអ្នកសារព័ត៌មានចំនួន៥០នាក់ ដែលពួកគេភាគច្រើនត្រូវបានស្នើឡើងដើម្បីបំភ្លឺ

---

[18] **E9** ដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់រៀបចំសវនាការ, ១៧ មករា ២០១១។

[19] **E9** ដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់រៀបចំសវនាការ, ១៧ មករា ២០១១, ត្រង់កថាខណ្ឌទី២, ៦។

[20] **E9/10** សេចក្តីសង្ខេបអំពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើឡើង, ២៣ កុម្ភៈ ២០១១, ត្រង់កថាខណ្ឌទី២។

[21] **E9/4/4** បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើឡើង, ១៥ កុម្ភៈ ២០១១។ **E9/10** សេចក្តីសង្ខេបអំពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើឡើង, ២៣ កុម្ភៈ ២០១១។ **E9/10.1** ឧបសម្ព័ន្ធ ឃៈ សេចក្តីសង្ខេបអំពីសាក្សី ដោយមានចំណុចនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ - ក្រុមមេធាវីការពារក្តី នួន ជា, ២៣ កុម្ភៈ ២០១១។

តែអំពី "ស្ថានភាពមុនឆ្នាំ១៩៧៥" ក្នុងប្រទេសកម្ពុជា ឬទង្វើរបស់សហរដ្ឋអាមេរិកនៅក្នុងរយៈពេលនោះតែប៉ុណ្ណោះ។

១០- ដូចដែលសហព្រះរាជអាជ្ញាបានធ្វើសេចក្តីសង្កេត នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងការដាក់ឯកសាររបស់មេធាវីការពារក្តីថា បញ្ជីសាក្សីដែលបានស្នើ គឺមិនទាន់គ្រប់គ្រាន់ទេ ដែលសំខាន់គឺមានបីយ៉ាង៖ (១) បញ្ជីមិនមានលក្ខណៈស្ពាពរទេ តែផ្ទុយទៅវិញ បានផ្តល់នូវសាក្សីជាច្រើនដែលទាក់ទងនឹងអ្វីដែលមេធាវីការពារក្តីបានប្រើពាក្យថា "ប្រភេទដែលធ្វើឡើងវិញជាថ្មីម្តងទៀត" ហើយដោយបាន "បំភ្លេចចោលដោយមានចេតនា"យ៉ាងច្បាស់ ចំពោះសិទ្ធិបុរិមាលើសាក្សីទាំងនោះ (២) ក្នុងករណីភាគច្រើន គឺសេចក្តីសង្ខេបនានាមិនបានផ្តល់នូវព័ត៌មានលម្អិតឲ្យបានគ្រប់គ្រាន់អំពីលក្ខណៈនៃសក្ខីកម្មរបស់សាក្សីដែលបានស្នើដើម្បីឲ្យភាគីនានាអាចយល់បានថា តើសក្ខីកម្មរបស់សាក្សីដែលបានពោលអះអាងនោះមានការជាប់ទាក់ទងទៅនឹងបញ្ហាផ្សេងៗនៅក្នុងសវនាការជំនុំជម្រះក្តីដែរ ឬទេ (៣) មេធាវីការពារក្តីមិនបានផ្តល់ពេលវេលាប៉ាន់ស្មាន សម្រាប់ការផ្តល់សក្ខីកម្មរបស់សាក្សីទាំងឡាយដែលខ្លួនបានស្នើឡើងនោះឡើយ[22]។ បន្ថែមពីលើនេះ ព័ត៌មានសម្រាប់ការទំនាក់ទំនងដែលបានផ្តល់មកដោយមេធាវីការពារក្តី ជាមួយនឹងសាក្សីដែលបានស្នើសុំដែលស្តីពីស្ថានភាពកាលពីមុនឆ្នាំ១៩៧៥នោះ គឺមានរយៈពេលជាងសាមសិបឆ្នាំទៅហើយ ដែលចាស់ហួសពេល ឬមិនមានលក្ខណៈគ្រប់គ្រាន់នោះទេ[23]។ សហព្រះរាជអាជ្ញាក៏បានដាក់ជូនផងដែរនូវការជំទាស់ទៅនឹងសាក្សីមួយចំនួនក្នុងចំណោមសាក្សីទាំងនោះទាំងដោយផ្អែកលើមូលដ្ឋានជាក់លាក់ និងទៅតាមប្រភេទផង[24]។

---

[22] ឯកសារលេខ **E9/14/1/1**, ការជំទាស់របស់សហព្រះរាជអាជ្ញា ទៅនឹងសាក្សីនឹងអ្នកជំនាញដែលបានស្នើសុំដោយភាគីដទៃទៀត ដោយមានឧបសម្ព័ន្ធ ការសម្ងាត់ ចំនួន១១ ភ្ជាប់ជាមួយផង, ចុះថ្ងៃទី៧ មីនា ២០១១, កថាខណ្ឌទី១៣ ដល់ ១៧។

[23] ឯកសារលេខ **E9/14/4.4** ឧបសម្ព័ន្ធ ក :បញ្ជីសាក្សីដែលស្នើសុំ, ចុះថ្ងៃទី១៥ កុម្ភៈ ២០១១។ ឧទាហរណ៍ដូចជាព័ត៌មានសម្រាប់ការទំនាក់ទំនងតែមួយគត់ដែលបានផ្តល់ជូនដោយមេធាវីការពារក្តីសំរាប់សាក្សីដែលធ្វើការឲ្យអង្គការ UNICEF នៅដើមទស្សវត្សរ៍ឆ្នាំ១៩៧០ នៅក្នុងក្រុងភ្នំពេញ គឺជាការិយាល័យនៃអង្គការ UNICEF នៅទីក្រុងញូយ៉ក។ ចំពោះសាក្សីទាំងឡាយដែលធ្វើការឲ្យរដ្ឋាភិបាលបរទេសនានា ក្នុងទីក្រុងភ្នំពេញនៅក្នុងអម្លុងពេលជាមួយគ្នានោះ មេធាវីការពារក្តីគ្រាន់តែបានចុះនៅក្នុងបញ្ជីថាក្រសួងការបរទេសសំរាប់ប្រទេសរបស់ពួកគេប៉ណ្ណោះ។

[24] ឯកសារលេខ **E9/14/1/1**, ការជំទាស់របស់សហព្រះរាជអាជ្ញា ទៅនឹងសាក្សីនឹងអ្នកជំនាញដែលបានស្នើសុំដោយភាគីដទៃទៀត ដោយមាន ឧបសម្ព័ន្ធ ការសម្ងាត់ចំនួន១១ ភ្ជាប់ជាមួយផង, ចុះថ្ងៃទី៧ មីនា ២០១១ (និងឧបសម្ព័ន្ធនានាដែលពាក់ព័ន្ធ) ។ ឯកសារលេខ E9/14/1/1, ការជំទាស់បន្ថែមទៀតនិងសេចក្តីសង្កេត របស់សហព្រះរាជអាជ្ញា ទៅនឹងសាក្សី និងអ្នកជំនាញដែលបានស្នើសុំដោយភាគីដទៃទៀត ដោយមានឧបសម្ព័ន្ធ ការសម្ងាត់ ចំនួន១១ ភ្ជាប់ជាមួយផង, ចុះថ្ងៃទី១១ មីនា ២០១១ ។

១១- ទាក់ទងនឹងសាក្សីទាំងឡាយដែលមេធាវីពោលអះអាងថា នឹងត្រូវមកផ្តល់សក្ខីកម្មទាក់ទងអំពី "ស្ថានភាពមុនឆ្នាំ១៩៧៥"នោះ សហព្រះរាជអាជ្ញាបានកត់សម្គាល់ឃើញថា សេចក្តីសង្ខេបនៃសក្ខីកម្មសាក្សីដែលបានស្នើឡើង បានបញ្ជាក់ថា សាក្សីអាចផ្តល់ជូនពីការយល់ដឹងយ៉ាងជ្រាលជ្រៅអំពីស្ថានភាពមុនឆ្នាំ១៩៧៥ ក៏ប៉ុន្តែមិនបាន "*បញ្ជាក់ច្បាស់អំពីស្ថានភាពទាំងនោះ ឬមិនបានពន្យល់ថា តើសក្ខីកម្មទាំងនោះមានការទាក់ទងបែបដូចម្តេចខ្លះទៅនឹងដីកាដំណោះស្រាយនោះទេ*"[25]។ ពាក់ព័ន្ធនឹងសាក្សីទាំងនោះដែលមេធាវីការពារក្តីបានពោលអះអាងថា នឹងផ្តល់សក្ខីកម្មអំពីគោលនយោបាយបរទេស និងកិច្ចប្រតិបត្តិការរបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជានោះ សហព្រះរាជអាជ្ញាបានធ្វើការសង្កេតស្រដៀងគ្នានេះដែរថា "*នួន ជា ខកខានមិនបានធ្វើការបញ្ជាក់អំពីមូលហេតុថាតើហេតុអ្វីបានជាខ្លួនចង់ស្នើសុំនូវសាក្សីទាំងនេះ ឬមិនបានបញ្ជាក់ពីចំណុចជាក់លាក់នានានៅក្នុងដីកាដំណោះស្រាយដែលពួកគេនឹងត្រូវផ្តល់សក្ខីកម្ម*"[26]។ ការរៀបរាប់អំពីសាក្សីរបស់មេធាវីការពារក្តីដែលពួកគេបានលើកឡើងអះអាង អាចផ្តល់ជូននូវព័ត៌មានស្តីពីបញ្ហានានាដែលទាក់ទងទៅនឹងបរិបទ ឬប្រវត្តិសាស្ត្រផ្សេងទៀតនោះ គឺមានគុណវិបត្តិស្រដៀងគ្នា[27]។

១២- កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ មេធាវីការពារក្តីបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដាក់បន្ថែមនូវប្រធានបទនានាក្នុងប្រភេទដែលមានលក្ខណៈទូលំទូលាយដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ អាចរួមបញ្ចូលក្នុងវគ្គទាំងបួននៃសវនាការលើកដំបូង លើសំណុំរឿងលេខ០០២/១[28]។ ប្រធានបទបន្ថែមដែលបានស្នើសុំទាំងនេះ គឺរួមមានទិដ្ឋភាពខាងប្រវត្តិសាស្ត្រនានា "ដែលមានផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលចំពោះប្រទេសកម្ពុជា *នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេល*នៃរបបកម្ពុជាប្រជាធិបតេយ្យ"[29]។

---

[25] ឯកសារលេខ **E9/14/1/1**, ការជំទាស់របស់សហព្រះរាជអាជ្ញា ទៅនឹងសាក្សីនិងអ្នកជំនាញដែលបានស្នើសុំដោយភាគីដទៃទៀត ដោយមានឧបសម្ព័ន្ធ ការសំងាត់ ចំនួន១១ ភ្ជាប់ជាមួយផង, ចុះថ្ងៃទី៧ មីនា ២០១១, កថាខណ្ឌទី២២។

[26] ឯកសារលេខ **E9/14/1/1**, ការជំទាស់របស់សហព្រះរាជអាជ្ញា ទៅនឹងសាក្សីនឹងអ្នកជំនាញដែលបានស្នើសុំដោយភាគីដទៃទៀត ដោយមានឧបសម្ព័ន្ធ ការសំងាត់ ចំនួន១១ ភ្ជាប់ជាមួយផង, ចុះថ្ងៃទី៧ មីនា ២០១១, កថាខណ្ឌទី២៤។

[27] ឯកសារលេខ **E9/14/1/1**, ការជំទាស់របស់សហព្រះរាជអាជ្ញា ទៅនឹងសាក្សីនឹងអ្នកជំនាញដែលបានស្នើសុំដោយភាគីដទៃទៀត ដោយមានឧបសម្ព័ន្ធ ការសំងាត់ ចំនួន១១ ភ្ជាប់ជាមួយផង, ចុះថ្ងៃទី៧ មីនា ២០១១, កថាខណ្ឌទី២៧ ដល់ ២៩។

[28] ឯកសារលេខ **E89/1**, ញត្តិធ្វើឡើងដើម្បីគាំទ្រចំពោះ "ញត្តិរបស់ អៀង សារី ដែលស្នើសុំឲ្យដាក់ប្រធានបទថ្មីបន្ថែមទៀតសំរាប់សវនាការនៅក្នុងកាលវិភាគនៃសវនាការ" និងសំណើសុំឲ្យដាក់ប្រធានបទថ្មីបន្ថែមទៀត ចុះថ្ងៃទី២៥ ឧសភា ២០១១។

[29] ឯកសារលេខ **E89/1**, ញត្តិធ្វើឡើងដើម្បីគាំទ្រចំពោះ "ញត្តិរបស់ អៀង សារី ដែលស្នើសុំឲ្យដាក់ប្រធានបទថ្មីបន្ថែមទៀតសំរាប់សវនាការនៅក្នុងកាលវិភាគនៃសវនាការ", និងសំណើសុំឲ្យដាក់ប្រធានបទថ្មីបន្ថែមទៀត, ចុះថ្ងៃទី២៥ ឧសភា ២០១១ ,ត្រង់កថាខណ្ឌទី ៣,៧,៨ ។

១៣- កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បដិសេធមិនព្រមអនុញ្ញាតលើសំណើ "នៅក្នុងដំណាក់កាលនេះ"នោះទេ ប៉ុន្តែបានថ្លែងថា"បញ្ហានានាដែលទាក់ទងនឹងបរិបទ និង ព្រឹត្តិការណ៍នានាដែលមិនស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អវតក នឹងត្រូវបានអង្គជំនុំជម្រះ ពិនិត្យពិចារណា តែនៅពេលណាដែលមានការបង្ហាញឱ្យឃើញថាមានការទាក់ទងទៅនឹងបញ្ហាដែល ស្ថិតនៅក្នុងវិសាលភាពនៃយុត្តាធិការរបស់ អវតក និងទៅនឹងវិសាលភាពនៃការជំនុំជម្រះក្តីដូចដែល បានកំណត់ដោយអង្គជំនុំជម្រះតែប៉ុណ្ណោះ"[30]។

១៤- កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើសំណើចុះថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ២០១១ ដែលស្នើឡើងដោយមេធាវីការពារក្តីរបស់ នួន ជា ដែលសុំឱ្យធ្វើការស៊ើបសួរ បន្ថែមអនុលោមតាមវិធាន៩៣នៃវិធានផ្ទៃក្នុង[31]។ សំណើសុំរបស់មេធាវីនេះបានលើកឡើងដដែលៗនូវ ការសំអាងដែលបានលើកកាលពីមុនដោយបញ្ជាក់ថា កិច្ចស៊ើបសួររបស់តុលាការ គឺមានកំហុស និង មានការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំមួយចំនួន ក្នុងចំណោមសំណើសុំទាំង ឡាយឱ្យធ្វើកិច្ចស៊ើបសួរទាំង២៦របស់ខ្លួន ដែលជាការបង្ហាញឱ្យឃើញពីការខកខានមួយមិនបាន ស៊ើបអង្កេតទៅលើភ័ស្តុតាងដោះបន្ទុក[32]។ ជាការឆ្លើតប សហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ ថា មេធាវីការពារក្តីខកខានក្នុងការបង្ហាញឱ្យឃើញថា នៅក្នុងសំណុំរឿងមិនមានព័ត៌មានគ្រប់គ្រាន់ ដែលទាក់ទងអំពីការផ្គត់ផ្គង់ម្ហូបអាហារ ស្ថានភាពនៃការរស់នៅ និងអំពីបញ្ហាដែលទាក់នឹងប្រវត្តិដើម ឬបរិបទដូចនេះ[33]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ជនជាប់ចោទបានមានឱកាសយ៉ាង ច្រើនគ្រប់គ្រាន់ នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរដែលមានរយៈពេលដល់ទៅជិតពីរឆ្នាំកន្លះ សម្រាប់ ធ្វើសំណើសុំឱ្យសហចៅក្រមស៊ើបអង្កេតបំពេញគ្រប់រាល់កិច្ចស៊ើបសួរទាំងអស់ ដែលជនជាប់ចោទ ចាត់ទុកថាមានការជាប់ទាក់ទង និងសម្រាប់ធ្វើការប្តឹងតវ៉ាទៅអង្គបុរេជំនុំជម្រះប្រឆាំងនឹងការ បដិសេធណាមួយរបស់សហចៅក្រមស៊ើបអង្កេត នៅពេលដែលខ្លួនយល់ឃើញថាចាំបាច់។ ជនជាប់ ចោទមិនបានបង្ហាញឱ្យឃើញថាតើហេតុអ្វីបានជាឥឡូវនេះអង្គជំនុំជម្រះសាលាដំបូងត្រូវតែយល់ព្រម

---

[30] ឯកសារលេខ E93, សេចក្តីណែនាំជាមុនៗពេលសវនាការលើកដំបូងស្តីពីសាក្សីដែលបានស្នើសុំ, ចុះថ្ងៃទី៣ មិថុនា ២០១១, ត្រង់ទំព័រ២។

[31] ឯកសារលេខ E88, សំណើសុំរួមលើកដំបូងសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម, ចុះថ្ងៃទី១៨ ឧសភា ២០១១។ ឯកសារលេខ E116 , សេចក្តីសំរេចលើញត្តិរបស់ នួន ជាស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារលេខE51/3, E82, E88, E92), ចុះថ្ងៃទី ៩ កញ្ញា ២០១១។

[32] ឯកសារលេខ**E116,** សេចក្តីសម្រេចលើញត្តិរបស់ នួន ជា ស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារលេខ E51/3, E82, E88 និង E92), ចុះថ្ងៃទី ៩ កញ្ញា ២០១១ ត្រង់កថាខណ្ឌទី៥។

[33] E88/2 ចម្លើយសហព្រះរាជអាជ្ញា ទៅនឹងសំណើរួមលើកទី១របស់នួន ជា ដែលសុំបំពេញកិច្ចចុះថ្ងៃទី៣ ខែមិថុនា ២០១១ កថាខណ្ឌ២០។

ទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរជាក់លាក់ប៉ុណ្ណោះ ដើម្បីឲ្យធានាថាការជំនុំជម្រះក្តីបានប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌"[34]។

១៥- កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចេញនូវ "បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីផ្នែកខ្លះ សម្រាប់សវនាការលើកដំបូង នៅក្នុងសំណុំរឿងលេខ ០០២"[35]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា សាក្សីដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីនេះគឺទាក់ទងនឹងប្រធានបទចំនួនបួនដំបូងដែលត្រូវធ្វើការពិចារណានៅក្នុងសវនាការជំនុំជម្រះក្តី។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ផងដែរថា "សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលទាក់ទងទៅនឹងផ្នែកដែលនិយាយពីអង្គហេតុសម្រាប់សវនាការលើកដំបូងនៅក្នុងសំណុំរឿងលេខ០០២ (ដែលទាក់ទងទៅនឹងការជម្លៀសប្រជាជននៅដំណាក់កាលទីមួយ និងទីពីរ) នឹងត្រូវធ្វើការប្រាស្រ័យទាក់ទងទៅកាន់ភាគីនានានៅពេលក្រោយ"[36]។

១៦- កាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ ជាការឆ្លើយតបទៅនឹងសំណើមួយដែលធ្វើឡើងដោយមេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យមេធាវីការពារក្តីដាក់ជូននូវបញ្ជីឈ្មោះសាក្សីបន្ថែមមួយ ដែលខ្លួនបានយល់ឃើញថាមានការពាក់ព័ន្ធទៅនឹងវគ្គនៃសវនាការ ដែលកំពុងតែធ្វើឡើងស្តីពីប្រវត្តិសាស្ត្រ[37]។ នៅថ្ងៃបន្ទាប់មក មេធាវីការពារក្តីបានដាក់នូវបញ្ជីមួយដែលមានសាក្សីចំនួន៤៧នាក់ ដែលទាក់ទងនឹងបរិបទស្តីពីប្រវត្តិសាស្ត្រ ដែលសាក្សីទាំងនោះមាននៅក្នុងបញ្ជីសាក្សីរបស់មេធាវីការពារក្តីដំបូងហើយ។ ទោះបីជាត្រូវបានផ្តល់ជូននូវឱកាសបែបនេះ និងទោះបីជាត្រូវបានផ្តល់ដំណឹងឲ្យបានដឹងអំពីមានគុណវិបត្តមួយចំនួននៅក្នុងការដាក់ឯកសារស្តីពីសាក្សីពីលើកមុននោះក្តី ក៏នៅក្នុងបញ្ជីសាក្សីបន្ថែមនោះ នៅតែខកខាន*សារជាថ្មីម្តងទៀត* ក្នុងការអនុវត្តតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសាក្សីដែលបានស្នើសុំ គឺនៅត្រង់ថា មេធាវីការពារក្តីមិនបានផ្តល់នូវព័ត៌មានណាមួយបន្ថែម

---

[34] ឯកសារលេខ **E116** , សេចក្តីសំរេចលើបណ្តឹងរបស់ នួន ជា ស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារលេខE51/3, E82, E88 និង E92), ចុះថ្ងៃទី ៩ កញ្ញា ២០១១ ត្រង់កថាខណ្ឌទី១៩។

[35] ឯកសារលេខ **E131/1.1**,ឧបសម្ព័ន្ធ ការសម្គាត់ ក៖ ផ្នែកខ្លះនៃបញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសំរាប់សវនាការលើកដំបូងក្នុង សំណុំ រឿងលេខ០០២, ចុះថ្ងៃទី២៥ តុលា ២០១១។

[36] ឯកសារលេខ **E131/1.1**,ឧបសម្ព័ន្ធ ការសម្គាត់ ក៖ ផ្នែកខ្លះនៃបញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសំរាប់សវនាការលើកដំបូងក្នុង សំណុំ រឿងលេខ០០២, ចុះថ្ងៃទី២៥ តុលា ២០១១។

[37] ឯកសារលេខ **E1/40.1**, ប្រតិចារិក ចុះថ្ងៃទី ៨ កុម្ភៈ ២០១២, ត្រង់កថាខណ្ឌទី៣២, ជួរបន្ទាត់ទី៣២-៣៥ និង៣៣ ហើយនិងជួរបន្ទាត់ទី១-៩។

ស្តីពីថាតើសក្ខីកម្មរបស់សាក្សីដែលបានស្នើសុំនោះមានជាប់ទាក់ទងយ៉ាងដូចម្តេចខ្លះ ជាមួយនឹងបញ្ហានៅក្នុងសវនាការ[38]។ កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលនូវសំណើសុំរបស់មេធាវីការពារក្តី: "សាក្សីទាំងនេះត្រូវបានពិនិត្យពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងពេលធ្វើបញ្ជីសាក្សីបណ្តោះអាសន្នរបស់ខ្លួន ហើយដែលការដាក់ឯកសាររបស់មេធាវី នួន ជា មិនបានធ្វើការបង្ហាញឲ្យឃើញអំពីថាតើហេតុអ្វីបានជាសាក្សីណាម្នាក់ ក្នុងចំណោមសាក្សី៤៧នាក់ គួរតែត្រូវបានធ្វើការស្តាប់ចម្លើយជាបន្ទាន់"[39]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងក៏បានធ្វើការកត់សម្គាល់ដែរថា រាល់សាក្សីដែលបានស្នើសុំទាំងអស់កំពុងស្ថិតនៅក្នុងការពិនិត្យពិចារណារបស់អង្គជំនុំជម្រះជាដដែលនៅឡើយរហូតដល់ពេលត្រូវបានធ្វើការកោះហៅ ឬត្រូវបានបដិសេធ និងថាអង្គជំនុំជម្រះនឹងចេញនៅក្នុងពេលដ៏ខ្លីខាងមុខនេះនូវបញ្ជីលើកទីមួយរបស់ខ្លួន ស្តីពីសាក្សីអ្នកជំនាញ និង/ឬដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធ[40]។

១៧- កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ មេធាវីការពារក្តីបានដាក់នូវសំណើភ្លាមៗមួយដែលសុំឲ្យធ្វើការកោះហៅសាក្សីបន្ថែមមួយចំនួនដើម្បីឲ្យមកផ្តល់សក្ខីកម្មដូចជាបញ្ហាដែលទាក់ទងនឹងប្រវត្តិសាស្ត្រជាដើម។ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ នួន ជា បានអាននូវសេចក្តីថ្លែងមួយដែលជាសេចក្តីសង្ខេបនៃឯកសារដែលបានដាក់នោះ ហើយបានប្រកាសជូនដំណឹងថា គាត់នឹងប្រកែកមិនព្រមបន្តការឆ្លើយទៅនឹងសំនួរផ្សេងៗទេ លុះត្រាតែអង្គជំនុំជម្រះយល់ព្រមអនុញ្ញាតរាល់សំណើសុំទាំងអស់របស់ខ្លួនសិន[41]។

## III. ទន្លីករណ៍

## ក. មេធាវីការពារក្តីបានជឿដោយខុសទៅលើភ័ស្តុតាងស្តីពីប្រវត្តិសាស្ត្រ ដែលមិនត្រូវបានអនុញ្ញាតឲ្យមានតទៅទៀតឡើយ

[38] ឯកសារលេខ **E155/1.1**, បញ្ជីសាក្សីបន្ថែមដែលពាក់ព័ន្ធនឹងប្រវត្តិដើម, ចុះថ្ងៃទី៩ កុម្ភៈ ២០១២។

[39] ឯកសារលេខ **E172**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៧ កុម្ភៈ ២០១២, ត្រង់ទំព័រ៤។

[40] ឯកសារលេខ **E172**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៧ កុម្ភៈ ២០១២, ត្រង់ទំព័រ៤។

[41] ឯកសារលេខ **E1/50.1**, ប្រតិចារិក, ចុះថ្ងៃទី១៩ មីនា ២០១២, ត្រង់កថាខណ្ឌទី៥-១០,១៧-១៩ និង២៣។

១៨- មេធាវីការពារក្ដីបានស្នើឲ្យអង្គជំនុំជម្រះ "កុំទាន់បិទផ្នែកដែលស្ដីពីប្រវត្ដិដើមនៅក្នុងវគ្គសវនាការលើកដំបូង"[42]។ សំណើសុំនេះបានផ្អែកទៅលើការអះអាងខុសថាបញ្ហានានាអំពីប្រវត្ដិដើមអាចនឹងមិនត្រូវបានគេលើកយកមកនិយាយតទៅទៀតទេនៅក្នុងសវនាការនេះ។ រីឯអង្គជំនុំជម្រះវិញបានបែងចែកការសួរសំនួរទៅកាន់ជនជាប់ចោទទៅជាផ្នែកៗដោយជាក់លាក់ ដែលចាប់ផ្ដើមពីប្រវត្ដិដើម អង្គជំនុំជម្រះក៏បានណែនាំផងដែរ ឲ្យធ្វើការសួរដេញដោលចំពោះសាក្សីនានាលើរាល់បញ្ហាទាំងអស់ដែលទាក់ទងទៅនឹងកថាខណ្ឌផ្សេងៗនៃដីកាដំណោះស្រាយ នៅក្នុងសំណុំរឿងលេខ០០២/១[43]។ ការិយាល័យសហព្រះរាជអាជ្ញាបានធ្វើការពន្យល់អំពីការយល់ឃើញរបស់ខ្លួនអំពីបញ្ហានេះ នៅក្នុងសវនាការ[44] ហើយមេធាវីការពារក្ដីអន្ដរជាតិរបស់ នួន ជា ហាក់ដូចជាប្រកាន់នូវជំហរនេះដូចគ្នាដែរ នៅក្នុងពេលធ្វើសេចក្ដីថ្លែងកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២៖ "យើងខ្ញុំសន្មតថា យើងខ្ញុំនឹងត្រូវបានអនុញ្ញាតឲ្យសួរសំនួរទៅកាន់សាក្សីមួយចំនួន ដែលនឹងត្រូវបានធ្វើការស្ដាប់ចម្លើយនៅក្នុងពេលក្រោយៗទៀតនៅក្នុងសំណុំរឿងនេះ ជាពិសេស អ្នកជំនាញនានាអំពីបរិបទប្រវត្ដិដើមនេះ ដើម្បីនឹងអនុញ្ញាតឲ្យយើងខ្ញុំអាចត្រឡប់ និងពិនិត្យមើលជាថ្មីឡើងវិញទៅលើប្រធានបទជាពិសេសនេះនៅពេលស្ដាប់ចម្លើយសាក្សីផ្សេងៗទៀត ទោះបីជាសាក្សីទាំងនោះមិនត្រូវបានកោះហៅ ឬមិនត្រូវបានស្នើសុំឲ្យផ្ដល់សក្ខីកម្មអំពីវគ្គនៃសវនាការលើកដំបូងនេះក៏ដោយ"[45]។

១៩- តាមពិត អង្គជំនុំជម្រះបានរកឃើញនូវរាល់អង្គហេតុទាំងអស់ដែលទាក់ទងទៅនឹងសវនាការលើកដំបូងដែលសមស្របសម្រាប់ការសួរដេញដោលទៅលើសាក្សី ហើយមិនសំខាន់ថាតើពេលណាត្រូវ

---

[42] ឯកសារលេខ **E182,** សំណើ, កំណត់សម្គាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី១ និង៣៩។

[43] ឯកសារលេខ **E141** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង,ចុះថ្ងៃទី១៧ វិច្ឆិកា ២០១២ ត្រង់ទំព័រ៣, ("ដើម្បីជៀសវាងការស្នើឲ្យសាក្សីនិងអ្នកជំនាញនានាវិលត្រឡប់មកជាថ្មីម្ដងទៀត នៅក្នុងអម្លុងពេលនៃសំណុំរឿងលេខ០០២/០១, គួរបានធ្វើការសួរដេញដោលពួកគេនៅលើរាល់ប្រធានបទទាំងអស់ដែលបានដាក់បញ្ចូលនៅក្នុងសំណុំរឿងលេខ០០២/១, ដែលពួកគេបានដឹង ដោយប្រើលំដាប់លំដោយនៃប្រធានបទដូចគ្នាដដែល (ដូចដែលមានចែងក្នុងឧបសម្ព័ន្ធលេខ E124/7.1), ដើម្បីនាំផ្លូវនៅក្នុងការតាំងសំណួរ") ។

[44] ឯកសារលេខ **E1/50.1,** ប្រតិចារិក, ចុះថ្ងៃទី១៩ មីនា ២០១២, ត្រង់កថាខណ្ឌទី២០ ជួរបន្ទាត់ទី២៥ និង២១ ជួរបន្ទាត់ទី១-៩ ("សេចក្ដីសង្កេតតែមួយគត់ដែលខ្ញុំចង់បន្ថែមពីលើនេះនោះគឺមាន...វិធីដែលការជំនុំជម្រះក្ដីនេះនឹងត្រូវបន្ដធ្វើនោះគឺមានសាក្សីជាច្រើន...ច្រើននាក់ទៀតដែលមិនទាន់ត្រូវបានស្ដាប់ចម្លើយនៅឡើយ។ មិនដូចជនជាប់ចោទទេ ដែលយើងកំពុងរៀបចំរចនាសម្ព័ន្ធនៃសក្ខីកម្មរបស់ពួកគេនៅក្នុងវគ្គពិសេសមួយចំនួន នៅពេលដែលសាក្សីនានាចូលមកបង្ហាញខ្លួនពួកគេនឹងអាចលើកឡើងពីបញ្ហាដែលទាក់ទងនឹងប្រវត្ដិដើម បបក។ ហេតុដូចនេះ ត្រឹមម្រិតដែលជនជាប់ចោទស្នើនៅពេលអនាគតសុំកុំឲ្យមានសាក្សី ណាទៀត អាចលើកឡើងអំពីផ្នែកខាងមុខ --មុនខែមេសា ឆ្នាំ១៩៧៥ នោះគឺវាមិនត្រឹមត្រូវទេ ហើយខ្ញុំចង់ឲ្យបានប្រាកដថា រឿងនេះត្រូវបានចុះយ៉ាងច្បាស់លាស់នៅក្នុងកំណត់ហេតុ")។

[45] ឯកសារលេខ **E1/40.1,** ប្រតិចារិក ចុះថ្ងៃទី ៨ កុម្ភៈ ២០១២, ត្រង់ទំព័រ៤ , ជួរបន្ទាត់ទី២-៧ ។

កោះហៅសាក្សីឱ្យមកធ្វើសក្ខីកម្មនោះទេ តាមលក្ខខណ្ឌថាការតាំងសំនួរជាទូទៅគួរតែអនុវត្តតាមលំដាប់លំដោយដូចនៅក្នុងដីកាដំណោះស្រាយ ប្រយោជន៍ដើម្បីមានភាពច្បាស់លាស់[46]។ នៅពេលដែលមានសមាជិកនៃមេធាវីការពារក្តីណាម្នាក់ស្វែងរកសុំការបំភ្លឺ ដូចជាអំពីវិសាលភាពនៃការតាំងសំនួរ លោកប្រធានអង្គជំនុំជម្រះបានបញ្ជាក់ដដែលៗឡើងវិញអំពីជំហរជាមូលដ្ឋាននេះ[47]។ នៅក្នុងការណែនាំជាច្រើន អង្គជំនុំជម្រះសាលាដំបូងមានភាពច្បាស់លាស់ថា ព្រំដែនកំណត់នៃការតាំងសំនួរដែលអាចទទួលយល់ព្រមបានជាទូទៅ គឺលាតសន្ធឹងទៅលើរាល់បញ្ហាទាំងអស់ដែលទាក់ទងទៅនឹងសំណុំរឿងលេខ០០២/១[48] ។ ការសួរដេញដោលលើ កាំង ហ្កេកអ៊ាវ សាក្សីដំបូងនៅក្នុងវគ្គទីពីរនៃសវនាការ បានបញ្ជាក់អំពីការអនុវត្តនេះ នៅពេលដែលសាក្សីត្រូវបានសួរដេញដោលស្តីពីបញ្ហាប្រវត្តិសាស្ត្រ[49]។

២០- អាស្រ័យហេតុដូច្នេះ អង្គជំនុំជម្រះធ្លាប់បានទទួលស្គាល់ថាសក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលស្ថិតនៅក្រៅវគ្គសវនាការបច្ចុប្បន្ននេះ អាចត្រូវបង្ហាញបន្តនៅក្នុងសវនាការទាំងមូលបាន ឱ្យតែវាទាក់ទងទៅនឹងអង្គហេតុនានាដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំ

---

[46] ឯកសារលេខ **E1/33.1,** ប្រតិចារិក ចុះថ្ងៃទី២៥ មករា ២០១២, ទំព័រ៨២ (“នៅពេលតាំងសំនួរទៅកាន់សាក្សី ភាគីនានាត្រូវបានអនុញ្ញាតឱ្យសួរតែនៅក្នុងរង្វង់អង្គហេតុបានហើយ--តែអង្គហេតុដែលបានបញ្ជាក់រួចហើយនៅក្នុងឯកសារលេខ E124/7.2 ប៉ុណ្ណោះ , ហើយសូមណែនាំឱ្យភាគីនានាត្រៀមរៀបចំសំនួរផ្សេងៗរបស់ខ្លួន ដែលពាក់ព័ន្ធទៅនឹងកថាខណ្ឌទាំងឡាយដែលត្រូវបានចោទប្រកាន់ឱ្យបានស្របទៅតាមលំដាប់លំដោយរបស់វា ដោយចាប់ផ្តើមពីលេខតូចទៅលេខធំ”) ។ សូមអានផងដែរ ដូចគ្នានឹងខាងលើ, ទំព័រ៨៣ (“ ហើយសំនួរទាំឡាយត្រូវតែជាប់ទាក់ទងនឹងអង្គហេតុដែលពាក់ពន្ធទៅនឹងការដឹងរបស់សាក្សី ហើយថា សំនួរត្រូវតែមានការជាប់ទាក់ទងទៅនឹងអង្គហេតុជាក់ស្តែងដែលត្រូវបានបំបែក ហើយបានរៀបជាចំណាត់ថ្នាក់ដូចមាននៅក្នុងសំណុំរឿងលេខ០០២/១។ វគ្គដំបូងនៃសវនាការតោងតែឱ្យស្របទៅ តាមការណែនាំនេះ។ គឺនិយាយអំពីប្រវត្តិដើមនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មកភាគីនានាអាចដំណើរការទៅតាមលំដាប់លំដោយផ្សេងទៀត--ឬ ទៅតាមអង្គហេតុជាបន្តបន្ទាប់តាមដូចដែលមានចែងនៅក្នុងឯកសារលេខE124/7.2...ដើម្បីឱ្យងាយយល់ជាងនេះ គឺសំនួរទាំងនេះ...លំដាប់នៃសំនួរនានា គួរតែបានចាប់ផ្តើមស្របគ្នាជាមួយនឹងលំដាប់លំដោយនៃអង្គហេតុទាំងនេះ”)។

[47] ឯកសារលេខ **E1/34.1,** ប្រតិចារិក, ចុះថ្ងៃទី២៦ មករា ២០១២, ត្រង់ទំព័រ១៥។

[48] E1/35.1 ប្រតិចារិកចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ ទំព័រ៧៨ (អនុញ្ញាតឱ្យសួរ ប៉ុន្តែលោកមិនឱ្យយើងបានប្រាប់មិនឱ្យលោកពាក់ព័ន្ធលើបញ្ហានេះទៅនឹងសំណុំរឿងផ្សេងឡើយ។ ការសួរដេញដោលនៅក្នុងសំណុំរឿង០០២នេះទៀតសោតកំហិតត្រឹម០០២/០១តែប៉ុណ្ណោះដែលយើងបានកំណត់ឱ្យភាគីទាំងអស់ដឹងរួចហើយ។ ហើយសួរតែពាក់ព័ន្ធទៅសាក្សីដែលលោកគិតថាសាក្សីនឹងដឹងអង្គហេតុទាំងឡាយដែលគាត់បានដឹងពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះបានសម្រេចក្នុង០០២/០១។ សូមមើលផងដែរ E1/34.1 ប្រតិចារិកថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ ទំព័រ ១៥។

[49] សូមមើលឧទាហរណ៍ E1/50.1 ប្រតិចារិក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ៤០-៤១, ៤៣-៤៥ (សំណួរទៅសាក្សី កាំង ហ្កេចអ៊ាវ ព្រឹត្តិការណ៍ ១៩៧០-៧១) E1/51.1 ប្រតិចារិក ថ្ងៃទី២០ មីនា ២០១២ កថាខណ្ឌ៧-៩ (សំណួរទៅសាក្សី កាំង ហ្កេចអ៊ាវ ព្រឹត្តិការណ៍ ១៩៦៧-៧៤)។

រឿង០០២/០១។ ដូច្នេះ ដោយហេតុថាផ្នែកនៃសំណើនេះមានមូលដ្ឋាននៅលើការភ័ន្តច្រឡំ ទៅលើសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង នោះសំណើត្រូវបដិសេធចោល។

## ខ. មេធាវីការពារក្ដីខកខានម្ដងទៀត ក្នុងការចង្អុលភ័ស្ដុតាងថាតើហេតុអ្វីបានជាខ្លួនចាំបាច់ត្រូវស្នើសាក្សីនានា ដែលទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រ

២១-មេធាវីការពារក្ដីអះអាងថា អង្គជំនុំជម្រះសាលាដំបូង "បដិសេធមិនពិចារណាឱ្យបានទូលំទូលាយលើបរិបទប្រវត្តិសាស្ត្រនៅក្នុងអំឡុងពេលសវនាការ"[50]។ នៅក្នុងប្រយោគមុននេះ ក្នុងកថាខណ្ឌដដែល មេធាវីការពារក្ដីបានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានឯកភាពថា "បញ្ហាបរិបទខាងប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍នានា ដែលនៅក្រៅយុត្តាធិការពេលវេលារបស់ អវតក នឹងយកមកពិចារណា" ដរាបណា "ហេតុការណ៍ និងព្រឹត្តិការណ៍ទាំងនោះជាប់ពាក់ព័ន្ធ ដោយផ្ទាល់ទៅនឹងបញ្ហាក្រោមយុត្តាធិការរបស់ អវតក និងវិសាលភាពនៃការជំនុំជម្រះប៉ុណ្ណោះ"[51]។

២២-អំណះអំណាងរបស់មេធាវីការពារក្ដីដែលថា អង្គជំនុំជម្រះសាលាដំបូងបដិសេធមិនពិចារណាលើបញ្ហានានាដែលទាក់ទងទៅនឹង "បរិបទប្រវត្តិសាស្ត្រឱ្យបានទូលំទូលាយ" ដូចជា វិបាកនៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក, ការខ្វះខាតម្ហូបអាហារ និងទុរ្ភិក្ស នៅទីក្រុងភ្នំពេញ និងនៅប្រទេសកម្ពុជា ក្នុងរយៈពេលមួយរហូតដល់ខែមេសា ឆ្នាំ១៩៧៥ គឺខុសយ៉ាងជាក់ស្ដែង។ ផ្ទុយទៅវិញ រហូតមកដល់ពេលនេះ អង្គជំនុំជម្រះធ្លាប់បានស្ដាប់សក្ខីកម្មលើបញ្ហាបែបដូច្នោះ ទាំងពី នួន ជា[52] និងទាំងពី ប្រាក់ យុត[53]។

---

[50] **E182** សំណើ កំណត់សម្គាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៣។

[51] **E182** សំណើ កំណត់សម្គាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៣, ដោយបានដកស្រង់ពី **E93** សេចក្ដីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ, ថ្ងៃទី៣ មិថុនា ២០១១ ត្រង់ទំព័រទី២។

[52] *សូមអាន ឧទា.* **E1/21.1** ប្រតិចារឹក, ថ្ងៃទី១៣ ធ្នូ ២០១១ ត្រង់ទំព័រទី២៩ បន្ទាត់ទី ៩-១៤ (នួន ជា៖ "ពីព្រោះសភាពការណ៍ភ្នំពេញអត់បាយ អត់ស្បៀងតាំងពីឆ្នាំ១៩៧២។ អស់ហើយស្បៀងឆ្នាំ១៩៧៥ កើតបាតុកម្ម កូតកម្ម មនុស្សអត់ការធ្វើ អ្នកសុំទានច្រើន ទាហានអត់ប្រាក់ខែ។ ដូច្នេះ លន់ ណល់ គ្រប់គ្រងស្ថានការណ៍នេះមិនបានហើយប្រជាជនអត់បាយទៀត។")។ **E1/17.1** ប្រតិចារឹក, ថ្ងៃទី៦ ធ្នូ ២០១១ ត្រង់ទំព័រទី៨៣ បន្ទាត់ទី ១៥-១៨ (នួន ជា៖ "Bombs were dropped, we could not stay in the villages, we had to take refuge in the jungle for the period of two years when bombs were constantly dropped on our location.")។

[53] *សូមអាន ឧទា.* **E1/34.1** ប្រតិចារឹក, ថ្ងៃទី២៦ មករា ២០១២ ត្រង់ទំព័រទី៨២ បន្ទាត់ទី ៤-៨ (ប្រាក់ យុទ្ធ៖ "When I was in Kampot, it was rare that there was any food shortages because people had enough food to eat. And this is what I

២៣-លើសពីនេះ ជាថ្មីម្តងទៀត មេធាវីការពារក្តីខកខានមិនបានផ្តល់ព័ត៌មានជាក់លាក់ណាមួយស្តីពីចរិតលក្ខណៈនៃសក្ខីកម្មរបស់សាក្សីនានាដែលខ្លួនបានស្នើសុំ ដែលទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រនោះឡើយ ឬបែរជាបង្ហាញថាហេតុអ្វីបានជាចាំបាច់ត្រូវស្តាប់ចម្លើយសាក្សីទាំងនោះ។ បែបដូច្នេះ សាក្សីជាច្រើនដែលបានស្នើឡើងដោយមេធាវីការពារក្តី អាចត្រូវបានច្រានចោលយ៉ាងត្រឹមត្រូវ នៅក្រោមវិធាន៨៧.៣ ដោយហេតុថាវាជាន់គ្នា, មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ និងមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី។

២៤-អង្គជំនុំជម្រះធ្លាប់បានថ្លែងថា ក្នុងពេលឆាប់ៗនេះ ខ្លួននឹងផ្តល់ជូននូវការពន្យល់អំពីសាក្សីដែលត្រូវបានបដិសេធមួយចំនួន ហើយថាសាក្សីផ្សេងៗទៀតទាំងអស់កំពុងឋិតនៅក្នុងការពិចារណារហូតដល់ពេលដែលត្រូវសម្រេចកោះហៅ ឬសម្រេចបដិសេធ[54]។ ដូច្នេះ ការត្អូញត្អែររបស់មេធាវីការពារក្តីដែលថា "អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានផ្តល់មូលហេតុចំពោះសេចក្តីសម្រេចរបស់ខ្លួនក្នុងការមិនកោះហៅសាក្សីដែលស្នើឡើងដោយមេធាវីការពារក្តី" គឺបានធ្វើឡើងមុនពេលមកដល់[55]។ ទោះបីជាមេធាវីការពារក្តីបានទទួលស្គាល់ថា សេចក្តីសម្រេចលើសាក្សីទាំងនេះនឹងមកដល់នៅពេលខាងមុខក្តី ក៏ខ្លួននៅតែអះអាងថា "មេធាវីការពារក្តីត្រូវបានជូនដំណឹងក្រៅផ្លូវការដោយតំណាងរបស់អង្គជំនុំជម្រះសាលាដំបូង ថាសាក្សីទាំងនេះនឹងមិនត្រូវបានគេកោះហៅនោះទេ"[56]។ សហព្រះរាជអាជ្ញា មិនលាក់លៀម ចំពោះការប្រាស្រ័យទាក់ទង*ដោយភាគីតែម្ខាង* ដែលបានចោទប្រកាន់ដោយមេធាវីការពារក្តីនោះឡើយ ហេតុដូច្នោះ មិនអាចផ្តល់ការគោរពដល់ពួកគេឡើយ។

### គ. នេះគឺជាការប៉ុនប៉ងដ៏យឺតយ៉ាវមួយរបស់មេធាវីការពារក្តី ក្នុងការដាក់បណ្តឹងដែលមានវិការៈសាជាថ្មីឡើងវិញ

២៥-មេធាវីការពារក្តីអះអាងថា សំណើនេះមិនមែនជាការប៉ុនប៉ងដាក់បណ្តឹងសាជាថ្មីឡើងវិញ លើសេចក្តីសម្រេចពីមុនៗរបស់អង្គជំនុំជម្រះនោះទេ តែសំណើនេះ "គ្រាន់តែស្វែងរកការបង្ហាញដល់អង្គជំនុំ

witnessed working there. So I can say that people had food to eat, although, in some places, people may lack some food, but it's not really big shortages. And people can share the food.")។

[54] **E172** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៧ កុម្ភៈ ២០១២ ត្រង់ទំព័រទី៤។

[55] **E182** សំណើ កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៤។

[56] **E182** សំណើ កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៤ កំណត់សម្គាល់លេខ៨។

ជម្រះសាលាដំបូងថាភស្តុតាងដែលបានពិភាក្សានៅក្នុងញត្តិ *គឺ* "ជាប់ពាក់ព័ន្ធទៅនឹងបញ្ហានានាដែលឋិតនៅក្រោមយុត្តាធិការរបស់ អវតក និងវិសាលភាពនៃការជំនុំជម្រះដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង"[57]។ យ៉ាងណាក៏ដោយ នៅទំព័របន្ទាប់នេះ មេធាវីការពារក្តីលើកឡើងម្តងទៀតនូវការអះអាងរបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើខុសតាំងពីដំបូងអំពីៈ "បញ្ហា និងហេតុការណ៍ដែលតាមពិតទៅជាបញ្ហា និងហេតុការណ៍ដែលពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់ អវតក និងវិសាលភាពនៃការជំនុំជម្រះដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង"[58]។ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា នេះគឺពិតជានិយមន័យនៃការដាក់បណ្តឹងសាជាថ្មីហើយ។ តាមពិតទៅ កំណត់សម្គាល់ជើងទំព័រលេខ១១ទាំងមូល គឺជាការប៉ុនប៉ងរបស់មេធាវីការពារក្តីក្នុងការដាក់បណ្តឹងសាជាថ្មីលើសេចក្តីសម្រេចពីមុនៗរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានធ្វើការអះអាងថា "មូលហេតុរបស់អង្គជំនុំជម្រះសាលាដំបូង គឺមិនទុកចិត្តបាន" ហើយថា "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះមិនស្តាប់សក្ខីកម្មរបស់សាក្សីទាំងនេះ គឺមិនបានបញ្ជាក់"[59]។

២៦- ដូចដែលមានចែងនៅក្នុងផ្នែកប្រវត្តិនីតិវិធីខាងលើស្រាប់ អំណះអំណាងរបស់មេធាវីការពារក្តី ធ្លាប់ត្រូវបានពិចារណាពីមុនមករួចហើយ ក៏ត្រូវបានច្រានចោលដោយ កសចស, អង្គបុរេជំនុំជម្រះ ព្រមទាំងអង្គជំនុំជម្រះសាលាដំបូងផងដែរ ហើយមេធាវីការពារក្តីខកខានមិនបានបង្ហាញមូលដ្ឋានណាមួយតាមផ្លូវច្បាប់សម្រាប់ធ្វើការពិចារណារបស់អង្គជំនុំជម្រះចំពោះសេចក្តីសម្រេចមុនលើបញ្ហានេះទេ។

## ឃ. សិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវរបស់មេធាវីការពារក្តី មិនត្រូវបានសម្របសម្រួលទេ

២៧- គ្រប់ភាគីទាំងអស់ត្រូវបានផ្តល់នូវឱកាសស្មើៗគ្នា នៅក្នុងកិច្ចដំណើរការនីតិវិធី ដើម្បីឲ្យការដាក់ឯកសារ និងធ្វើការស្នើសុំសាក្សីនានារបស់ខ្លួន។ មានសាក្សីជាច្រើន ក្នុងចំណោមសាក្សីដែល

[57] **E182** សំណើ កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៣ កំណត់សម្គាល់លេខ៥ (សង្កត់ន័យបន្ថែមដូចដើម)។

[58] **E182** សំណើ កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៦ (សង្កត់ន័យបន្ថែមដូចដើម)។

[59] **E182** សំណើ កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៥ កំណត់សម្គាល់លេខ១១។

សហព្រះរាជអាជ្ញាបានស្នើ ក៏មិនត្រូវបានទទួលយកដោយអង្គជំនុំជម្រះសាលាដំបូងផងដែរ[60]។ វាក៏មិនមានតម្លៃអ្វីនោះទេដែលថាមានសាក្សីមួយរូបដែលមេធាវីការពារក្តីបានអះអាង ថាត្រូវបានគេដកចេញ ដែលតាមការជាក់ស្តែង មាននៅក្នុងបញ្ជីសាក្សីរបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់វគ្គសវនាការបច្ចុប្បន្ននេះ[61] ហើយសាក្សីប្រាំបី(០៨)រូប ក្នុងចំណោមសាក្សីដែលបានស្នើឡើងដោយមេធាវីការពារក្តី ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីវគ្គដំបូងនេះ[62]។

២៨- សិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវមិនបានបំរើ ដើម្បីការពារដល់ភាគីនានាឲ្យរួចផុតពីផលវិបាកទាំងឡាយដែលស្តែងចេញមកពី ការប្រព្រឹត្ត ការមិនប្រព្រឹត្ត ឬការខកខានរបស់ខ្លួនផ្ទាល់ដែលមិនបានធ្វើឲ្យត្រូវតាមសេចក្តីសម្រេច ឬសេចក្តីបង្គាប់របស់អង្គជំនុំជម្រះនោះទេ។ ដូចដែលបានពន្យល់នៅខាងលើនេះស្រាប់ មេធាវីការពារក្តីខកខានមិនបានធ្វើតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទេ ហើយបានដាក់ជូនទាំងទុក្ខសោកនូវឯកសារនានាដែលមានលក្ខណៈមិនពេញលេញគ្រប់គ្រាន់ ទាក់ទងទៅនឹងសាក្សីនានាដែលបានស្នើឡើងនោះ។ នៅពេលដែលដល់វេនខ្លួនត្រូវសួរសំណួរដល់ នួន ជា អំពីបញ្ហាប្រវត្តិសាស្ត្រ មេធាវីការពារក្តីបានស្នើសុំតែមួយរយៈពេលខ្លីប៉ុណ្ណោះសម្រាប់សំណួររបស់ខ្លួន ហើយបានជ្រើសរើសប្រើប្រាស់ពេលវេលានោះសម្រាប់ធ្វើការរុករកឲ្យឃើញនូវបញ្ហាពាក់ព័ន្ធជាបន្ទាប់បន្សំទៅវិញ ដូចជា បញ្ហាស្តីពីកុមារភាពរបស់ នួន ជា និងដំណើររបស់គាត់ទៅកាន់ព្រំដែនជាមួយនឹង ហេង សំរិន ជាដើម។ គឺវាពុំមែនជាបញ្ហាអ្វីណាមួយទាល់តែសោះ ដែលមេធាវីការពារក្តីត្រូវធ្វើសំណួរអំពីបញ្ហាប្រវត្តិសាស្ត្រ ដែលពេលនេះពួកគេបានអះអាងថាជាការសំខាន់នៅក្នុងសំណុំរឿងនេះ[63]។ បន្ថែមលើនេះ ខណៈដែលមេធាវីការពារក្តីមានឱកាសដើម្បីធ្វើការបង្ហាញឯកសារនានាស្តីពីបញ្ហាសារតារប្រវត្តិសាស្ត្រនោះ ពួកគេដាក់ឯកសារចំនួន០៦ ក្នុងបញ្ជីដែលមានឯកសារបួន ក្នុងចំណោមឯកសារទាំងនោះ គឺអាស្រ័យនៅលើការជំទាស់ ត្រូវបិតនៅក្រោម

[60] ជាឧទាហរណ៍ សាក្សី TCE-10 និង TCE-33។ *សូមប្រៀបធៀប* **E9/10.1** ឧបសម្ព័ន្ធយ៖ សេចក្តីសង្ខេបសាក្សី ជាមួយនឹងចំណុចនៃការចោទប្រកាន់ - ក្រុមមេធាវីការពារក្តីលោក នួន ជា, ថ្ងៃទី២៣ កុម្ភៈ ២០១១, *ជាមួយនឹង* **E9/4.2** ឧបសម្ព័ន្ធ២៖ បញ្ជីឈ្មោះអ្នកជំនាញរបស់ ក.ស.ព., ថ្ងៃទី២៨ មករា ២០១១។

[61] **E172** អនុស្សរណៈស្តីពី៖ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១, ថ្ងៃទី១៧ កុម្ភៈ ២០១២ (សាក្សី TCE 65)។

[62] **E131/1.1** សម្ងាត់ ឧបសម្ព័ន្ធ ក៖ ផ្នែកមួយនៃបញ្ជីសាក្សីអ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សវនាការដំណាក់ដំបូងនៃសំណុំរឿង ០០២, ថ្ងៃទី២៥ តុលា ២០១១។

[63] *សូមអាន* **E1/36.1** ប្រតិចារឹក, ថ្ងៃទី៣១ មករា ២០១២។ **E1/41.1** ប្រតិចារឹក, ថ្ងៃទី៩ កុម្ភៈ ២០១២។

ហើយបានធ្វើការជ្រើសរើសយកមិនបង្ហាញឯកសារពីរផ្សេងទៀតទេ នៅពេលដែលអង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យធ្វើដូច្នេះ[64]។

២៩- តាមពិតទៅ ការត្អូញត្អែររបស់មេធាវីការពារក្តីដែលថាវាជាទម្ងន់នៃសំណើរបស់ខ្លួន នោះគឺជាបញ្ហាមួយដែលពួកគេបានបង្កើតឡើងដោយខ្លួនឯងទេ។ គ្រាន់តែជាឧទាហរណ៍មួយ មេធាវីការពារក្តីបានអះអាងនៅក្នុងការដាក់ឯកសាររបស់ខ្លួនកាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ ដែលជាការឆ្លើយតបទៅនឹងការអនុញ្ញាតរបស់អង្គជំនុំជម្រះសាលាដំបូងឲ្យខ្លួនបានដាក់សាក្សីបន្ថែមនានា ដោយមានមូលហេតុជាលាយលក្ខណ៍អក្សរផង សម្រាប់ធ្វើការស្តាប់ចម្លើយ ថាការបង្ខំឲ្យទទួលយកពេលវេលាកំណត់ចំនួន២៤ម៉ោងនោះគឺ "មិនគ្រប់គ្រាន់ទេ" ហើយថា "ត្រូវការពេលវេលាច្រើនថែមទៀត"[65]។ តាមរយៈការទទួលស្គាល់របស់មេធាវីការពារក្តីផ្ទាល់ "គ្រប់សាក្សីទាំងអស់ដែលពីមុនត្រូវបានដាក់ក្នុងបញ្ជីសាក្សី នៅក្នុងសំណើដើមរបស់មេធាវីការពារក្តី ដូចដែលបានដាក់នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១", ជាការដាក់ឯកសារមួយដែល *លើសពីអ្វីៗទាំងអស់* តម្រូវឲ្យមានជា"សេចក្តីសង្ខេបនៃអង្គហេតុដែលសាក្សីនឹងត្រូវធ្វើសក្ខីកម្ម" ដែល "ត្រូវមាននូវភាពលម្អិតគ្រប់គ្រាន់ដែលអាចឲ្យអង្គជំនុំជម្រះ និងភាគីអាចយល់បានពេញនូវលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្មដែលបានស្នើសុំនោះ" ព្រមទាំង "ចំណុចនៃការចោទប្រកាន់ដែលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញដែលបានស្នើសុំនោះរំពឹងថានឹងមកផ្តល់សក្ខីកម្ម ហើយត្រូវបញ្ជាក់ផងដែរនូវលេខកថាខណ្ឌនៃដីកាដំណោះស្រាយ និងបទចោទជាក់លាក់ណាមួយ"[66]។ អាស្រ័យហេតុដូច្នេះ ជាងមួយឆ្នាំមកនេះ មេធាវីការពារក្តីគួរតែបានផ្តល់នូវយុត្តិកម្មជាលាយលក្ខណ៍អក្សរសម្រាប់ស្តាប់ចម្លើយសាក្សីទាំងនេះ តែមេធាវីការពារក្តីនៅតែមិនទាន់បានផ្តល់នូវយុត្តិកម្មដែលគេតម្រូវឲ្យមាននៅឡើយ ហើយពួកគេបានធ្វើការស្វែងរកដើម្បីទាមទារថាពួកខ្លួនត្រូវបានគេប្រព្រឹត្តមកលើដោយអយុត្តិធម៌។

៣០- ខណៈដែលមេធាវីការពារក្តីអាចនឹងមើលឃើញថាជាផលប្រយោជន៍របស់ខ្លួនក្នុងរយៈកាលខ្លី ឬរយៈកាលវែង ដើម្បីដាក់ខ្លួនចូលរួមដូចជាជនរងគ្រោះដែល"មិនត្រូវបានគេទុកអ្វីឲ្យមាននៅក្នុងដៃឡើយ"[67] ការពិតនោះគឺថា ការខកខានរបស់ពួកគេនៅក្នុងការធ្វើយុត្តិកម្មឲ្យបានគ្រប់គ្រាន់ជូនអង្គជំនុំជម្រះ

---

[64] *សូមអាន* **E1/50.1** ប្រតិចារឹក, ថ្ងៃទី១៩ មីនា ២០១២ ត្រង់ទំព័រទី ១០-១១។

[65] **E182** សំណើ កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៥ កំណត់សម្គាល់លេខ១១។

[66] **E9** ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ថ្ងៃទី១៧ មករា ២០១១ ត្រង់កថាខណ្ឌទី**២**, ៦។

[67] **E182** សំណើ កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៣៨។

សាលាដំបូង អំពីសេចក្តីត្រូវការរបស់ពួកគេចំពោះសាក្សីជាក់លាក់នានា ឬមួយក៏យកឱកាសដែលគេបានផ្តល់ឲ្យធ្វើជាទុន ហើយធ្វើយុត្តិកម្មលើសាវតារប្រវត្តិសាស្ត្រដែលត្រូវបានគេអនុញ្ញាតឲ្យធ្វើ ដែលគ្មាននរណាម្នាក់អាចធ្វើបានឡើយក្រៅតែពីពួកគេផ្ទាល់។ ពុំមានអំណះអំណាងណាមួយពាក់ព័ន្ធទៅនឹងភាពទាក់ទងដែលបានអះអាងអំពីសាវតារប្រវត្តិសាស្ត្រ នៅក្នុងករណីរបស់មេធាវីការពារក្តីនោះឡើយ ដែលត្រូវបានដាក់បញ្ចូលទៅក្នុងការដាក់ឯកសារភ្លាមៗ ដែលពីមុនមេធាវីការពារក្តីមិនអាចដាក់បាន។

៣១- បើមេធាវីការពារក្តីមានកង្វល់អំពី "សិទ្ធិជាសារវន្តក្នុងការបង្ហាញការការពារក្តី"[68] នោះខ្លួន ត្រូវធ្វើឲ្យល្អដើម្បីឲ្យខ្លួនឯងមានឱកាសដែលគេបានផ្តល់ឲ្យ ដើម្បីបង្ហាញការការពារក្តីហ្មត់ចត់ឲ្យបានពេញលេញជាងនេះ ជាជាងប៉ុនប៉ងរកដំណោះស្រាយទៅលើកំហុសរបស់ខ្លួន បន្ទាប់ពីមានអង្គហេតុពិតមកនោះ។ អ្វីដែលមេធាវីការពារក្តីកំពុងស្នើនេះ គឺមិនមែនភាពត្រឹមត្រូវនោះទេ គឺវាត្រូវតែបានធ្វើចាត់ទុកថាមានលក្ខណៈប្លែកពីធម្មតា និងជាលេសមិនព្រមធ្វើតាមសេចក្តីបង្គាប់ និងសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះនេះ។

## IV. ដំណោះស្រាយដែលបានស្នើសុំ

៣២- យោងតាមសំអាងហេតុនានាដូចបានថែងខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដោយសេចក្តីគោរព ដល់ឲ្យអង្គជំនុំជម្រះឲ្យបដិសេធសំណើរបស់មេធាវីការពារក្តីចោល៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |

[68] **E182** សំណើ កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី១៤។